ធ្វើនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១

# សេចក្តីប្រកាសពត៌មាន

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងផលប្រយោជន៍នៃក្រុមជនរងគ្រោះរួមគ្នាតែមួយនៅក្នុងដំណាក់កាលជំនុំជម្រះ សូមស្វាគមន៍ចំពោះសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ លើបណ្តឹងឧទ្ធរណ៍របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបានឯកភាពចំពោះទឡ្ហីករណ៍ភាគច្រើនដែលត្រូវបានប្រើប្រាស់នៅក្នុងបណ្តឹងឧទ្ធរណ៍ដាក់ជូនដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពមិនអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

ជាលទ្ធផល ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៧២៨ នាក់ត្រូវបានប្រកាសទទួលយក ដែលតាមរយៈសេចក្តីសម្រេចទាំងនេះ អង្គបុរេជំនុំជម្រះបានទទួលយកភាគច្រើនលើសលុបនៃជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីចូលរួមក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមនៅក្នុងសំណុំរឿង ០០២ មានចំនួនសរុប ៣៨៥០ នាក់។

ការកើនឡើងនៃចំនួនដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនបង្កជាឧបសគ្គទៅដល់ការគ្រប់គ្រងផ្នែកយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពនោះទេ។ ផ្ទុយមកវិញ វាជាការបញ្ជាក់អំពីតួនាទីដ៏មានសារៈសំខាន់ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តនៅក្នុងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។